00644947

E9/6/1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

**អនុស្សរណៈ:- អង្គជំនុំជម្រះសាលាដំបូង**

សាធារណៈ / Public

**ជូនចំពោះ:** **ក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន**

កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 16 / 02 / 2011

ម៉ោង (Time/Heure) : 14:05

មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ចម្លងជូន:** លោកប្រធាន និងលោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**ពី:** **Susan LAMB** មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** **ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេលដាក់ឯកសារតស្លុតាង** (ឯកសារលេខ E9/6)

យោងទៅលើសំណើសុំលេខ E9/6 ដែលបានដាក់កាលពីថ្ងៃព្រហស្បតិ៍ ទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្នើសុំពន្យារពេលក្នុងការដាក់បញ្ជីឈ្មោះសាក្សីរបស់ ខៀវ សំផន។ សំណើសុំនេះមួយផ្នែក ផ្អែកទៅលើបញ្ហាមិនទាន់បានទទួលបញ្ជីឈ្មោះសាក្សីរបស់ ក.ស.ព ជាភាសាបារាំង ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ កាលពីថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។ អនុស្សរណៈនេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំនេះ។ យោងតាមកាលបរិច្ឆេទចុងក្រោយ ដែលបានកំណត់ឲ្យភាគីក្នុងការដាក់ឯកសារ នៅក្នុងដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីត្រៀមរៀបចំសវនាការ (ឯកសារលេខ E9) ដែលបានចេញដំបូងបំផុត និងភាពជាប់គាំងនៃការបកប្រែភាសា ដោយក្រុមបកប្រែភាសា ដូចបានបញ្ជាក់កន្លងមក (ឯកសារលេខ E38) អង្គជំនុំជម្រះនឹងឆ្លើយតបទៅភាគីអំពីកាលបរិច្ឆេទចុងក្រោយ តាមរយៈអនុស្សរណៈ ទៅតាមករណីជាក់ស្តែងដើម្បីសម្រួលដល់ការរៀបចំផែនការ។ នេះគឺជាការកែប្រែទៅលើសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធនានានៅពេលខាងមុខ ។

អង្គជំនុំជម្រះយល់ឃើញថា ការអនុវត្តទៅតាមពេលវេលាដែលបានកំណត់នៅក្នុងវិធាន ៨០ (២) ដោយក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន មិនមែនរាំងស្ទះដោយបញ្ហាការពន្យារពេលក្នុងការបកប្រែឯកសារបញ្ជីឈ្មោះសាក្សី របស់ ក.ស.ព ជាភាសាបារាំង ឡើយ។ ដោយហេតុថាថ្ងៃផុតកំណត់ក្នុងការដាក់បញ្ជីឈ្មោះសាក្សីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង គឺជារយៈពេលមួយសមស្របដែលរំពឹងថាក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន បានចាប់ផ្តើមរៀបចំបញ្ជីឈ្មោះសាក្សីរបស់ខ្លួន មុនពេល ក.ស.ព ដាក់បញ្ជីឈ្មោះសាក្សីរបស់ពួកគេ ផ្អែកលើការសំអាងទៅលើសមត្ថភាពក្នុងការបំពេញការងារជាពីរភាសា របស់ក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ដើម្បីពិនិត្យទៅលើបញ្ជីឈ្មោះសាក្សីរបស់ ក.ស.ព នៅចន្លោះពេលនោះ។ ដោយហេតុថាបញ្ជីឈ្មោះសាក្សីរបស់ ក.ស.ព ទើបតែមានជាភាសាបារាំង នៅថ្ងៃនេះ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលយកនូវសំណើសុំពន្យារពេលរបស់ក្រុមមេធាវីការពារក្តីឱ្យលោកខៀវ សំផន រហូតដល់ថ្ងៃ សុក្រ ទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ដើម្បីបញ្ចប់ការរៀបចំបញ្ជីឈ្មោះសាក្សីរបស់ពួកគេ។

ដោយពិនិត្យឃើញថា ភាពជាប់គាំងនៃការបកប្រែភាសានៅក្នុងក្រុមបកប្រែភាសា គឺទាក់ទងទៅនឹងការបកប្រែឯកសារជាភាសាខ្មែរ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីឱ្យលោក ខៀវ សំផន ដាក់បញ្ជីឈ្មោះសាក្សីរបស់ខ្លួន និងបញ្ជីផ្សេងៗទៀត ជាភាសាអង់គ្លេស ឬភាសាបារាំង នៅដំណាក់កាលដំបូង។ ដោយឡែកបញ្ជីឈ្មោះសាក្សីជាភាសាខ្មែរ ត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងរយៈពេលមួយដ៏ឆាប់បំផុត។

អង្គជំនុំជម្រះសូមរំលឹកអំពីការជូនដំណឹងកាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ (ឯកសារលេខ E35) ដែលនៅក្នុងនោះ អង្គជំនុំជម្រះបានជូនដំណឹងថា ខ្លួននឹងបដិសេធរាល់សំណើទាំងអស់ដែលស្នើសុំអនុម័តយកនូវនីតិវិធីថ្មីមួយទៅលើនីតិវិធីដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងបច្ចុប្បន្ន។ ឯកសារថតចម្លងមួយច្បាប់ដែលភ្ជាប់មកជាមួយនឹងសេចក្តីជូនដំណឹងមុន ត្រូវបានភ្ជាប់មកជាមួយនឹងអនុស្សរណៈនេះ រួមទាំងឯកសារបកប្រែក្រៅផ្លូវការជាភាសាបារាំងមួយច្បាប់។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធនូវរាល់សំណើសុំផ្សេងៗដែលមាននៅក្នុងសំណើសុំលេខ E9/6 ។

សូមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C